**តុលាការកំពូល**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី

លេខ : ៤៤៣

ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០៥

សាលដីកា

លេខ : ៣៤៣

ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៦

# នាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជម្រះ ជាសាធារណៈ នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៦ ដោយមានសមាសភាពដូចតទៅ :

១- ឯកឧត្តម ខិន ឌុន្នី ជាប្រធាន

២- លោក ស៊ិន ឌឹម ជាចៅក្រម

៣- លោក យស់ សូខឿន ជាចៅក្រម

៤- លោក ម៉ុង មុន្នីចរិយា ជាចៅក្រមរបាយការណ៍

៥- លោក យូរ ឧត្តរា ជាចៅក្រម

ក្រឡាបញ្ជី

លោក ស៊ិន ភារៈ

តំណាងមហាអយ្យការ

លោក ឈួន ចាន់ថា ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ១៤៨ "ឃ" ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៥ នៃសំណុំរឿងរដ្ឋប្បវេណីលេខ២០១ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ រវាង :

-ដើមចោទឈ្មោះ អៀម ឈិន (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៧៧ឆ្នាំ ជាតិខ្មែរ មុខរបរជាងា ទីលំនៅសព្វថ្ងៃភូមិជ័យឧត្តម ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។ ឪពុកឈ្មោះ អៀម "ស" ម្តាយឈ្មោះជា "ស" ប្រពន្ធឈ្មោះតាំង មុំន ។ ផ្ទេរសិទ្ធិឱ្យឈ្មោះ លី សុវណ្ណ ។

-ចុងចម្លើយឈ្មោះ តាំង មុំន "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទស្រី អាយុ៧៦ឆ្នាំ ជាតិខ្មែរ មុខរបរជាងា ទីលំនៅសព្វថ្ងៃផ្ទះលេខ២៤៤ ក្រុម១៥ ភូមិបំព្រកខាងត្បូង សង្កាត់កាកាប ខណ្ឌដង្កោ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះប៊ុត "ស" ម្តាយឈ្មោះតាំង "ស" ប្តីឈ្មោះអៀម ឈិន ។

-មានមេធាវីលោក ស៊ឹម ស៊ីថាន

**កម្មវត្ថុ** : ប្តឹងលែងលះ និងបែងចែកទ្រព្យរួម ។

-បានឃើញបណ្តឹងសាទុក្ខលេខ៣៦៣ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៥ របស់ឈ្មោះ តាំង មុំន ប្តឹងមិនសុខចិត្តពីសាលដីការដ្ឋប្បវេណីលេខ១៤៨ ឈ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

-បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៤៤៣ ចុះថ្ងៃទី០២-១១-២០០៥ របស់តុលាការកំពូល ។

-តាមពាក្យបណ្តឹង ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៤ របស់ឈ្មោះ អៀម ឈិន ប្តឹងសុំលែងលះប្រពន្ធឈ្មោះតាំង មុំន ដោយហេតុថា លោកអៀម ឈិន បានបែកទីលំនៅជាមួយប្រពន្ធតាំងពីឆ្នាំ១៩៩៤ មកម្លេះ ម្យ៉ាងទៀតគ្រួសារនេះមានទ្រព្យសម្បត្តិដី និងផ្ទះ នៅភូមិបំប្រកខាងត្បូង សង្កាត់កាកាប ខ័ណ្ឌដង្កោ ក្រុងភ្នំពេញ ជាទ្រព្យសម្បត្តិរួម ហើយលោកយាយ តាំង មុំន មានកូនចិញ្ចឹមម្នាក់ ហើយលោកយាយ តាំង មុំន បានធ្វើលិខិតផ្ទេរសិទ្ធិឱ្យទៅកូនចិញ្ចឹមទទួល ដីនិងផ្ទះនោះ ទើបលោកតា អៀម ឈិន ប្តឹងសុំលែងលះ និងប្តឹងបដិសេធលិខិតផ្ទេរសិទ្ធិទាំងអស់នោះ លោកតា អៀម ឈិន និងលោកយាយ តាំង មុំន រៀបការតាំងពីឆ្នាំជំនាន់សង្គមរាស្ត្រនិយមមក ចំណែកដី និងផ្ទះនៅភូមិបំប្រកនោះ មានប័ណ្ណសំគាល់សិទ្ធិលេខ៤១៨៦០ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ១៩៩១មានទំហំ៤២អា ។ដើមចោទឈ្មោះអៀម ឈិន ប្តឹងសុំចែកទ្រព្យសម្បត្តិរួមជាពីរចំណែកស្មើគ្នា សុំបដិសេធលិខិតផ្ទេរសិទ្ធិទាំងអស់ និងសុំលែងលះប្រពន្ធ ។

-បានឃើញសាលក្រមរដ្ឋប្បវេណីលេខ២៩ ង ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៥ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងរបស់ឈ្មោះអៀម ឈិន ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៤ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-អោយឈ្មោះអៀម ឈិន និងឈ្មោះតាំង មុំន ផ្តាច់សមគ្គសង្វាសពីគ្នាចាប់តាំងពីថ្ងៃនេះតទៅ ។ តាមមាត្រា៣៩ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ។

៣-អោយឈ្មោះតាំង មុំន ស្ថិតនៅក្នុងភាពមេម៉ាយចំនួន៣០០ថ្ងៃ គិតពីថ្ងៃបែកលំនៅសង្វាស តាមមាត្រា៩ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ។

៤-ទ្រព្យសម្បត្តិរួមមានដីនិងផ្ទះ ស្ថិតនៅក្នុងភូមិបំប្រកខាងត្បូង សង្កាត់កាកាប ខ័ណ្ឌដង្កោ ក្រុងភ្នំពេញ ដែលមានទំហំ៤២អា ត្រូវបែងចែកជាពីរចំណែកជាពីរស្មើៗគ្នា ។

៥-ចំពោះលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លី ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៣ លិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លី ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៣ លិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៣ បដិសេធចោលជាអសារបង់ ចាប់តាំងពីថ្ងៃនេះតទៅ ។

៦-បង្គាប់អោយចុងចម្លើយបង់ប្រាក់ប្រដាប់ក្តីចំនួន៧.០០០រៀល ក្នុងនោះមានពន្ធចុះបញ្ជីក្តី និងពន្ធហ្វឹងចំនួន១៨.០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន២០០រៀល និងចំណាយលើអ្នករត់ដីកាកោះចំនួន៥.០០០រៀល សរុបទាំងអស់ចំនួន៧.០០០រៀល ដែលដើមចោទបានបង់រួចហើយ ។

៧-សាលក្រមនេះជំនុំជំរះជាសាធារណៈចំពោះមុខគូក្តីបើកផ្លូវអោយប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ០៣"ង" ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៥ របស់ឈ្មោះ តាំង ម៉ុន ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ០៩ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៥ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

-បានឃើញសាលដីការដ្ឋប្បវេណីលេខ១៤៨ "ឈ" ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៥ របស់ឈ្មោះ តាំង ម៉ុន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខ្វះអង្គហេតុនិងអង្គច្បាប់ ។

២-តំកល់សាលក្រមរដ្ឋប្បវេណីលេខ០៩"ង" ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៥ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

៣-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០រៀល ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួច គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង២.៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ៥.០០០៛ និងអាជ្ញាធរតុលាការ ៥.០០០៛ ។

៤-សាលដីកានេះជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៥ ចំពោះមុខចុងចម្លើយ និងតំណាងដើមចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៥ ចំពោះមុខតំណាងដើមចោទ កំបាំងមុខចុងចម្លើយតែចាត់ទុកជាចំពោះមុខ ។

-បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ៣៦៣ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៥ របស់ឈ្មោះ តាំង ម៉ុន ប្តឹងមិនសុខចិត្តពីសាលដីការដ្ឋប្បវេណីលេខ១៤៨"ឈ" ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

-បានឃើញសារណា ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៥ របស់ឈ្មោះតាំង ម៉ុន ។

-បានឃើញសារណាតប ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៦ របស់ឈ្មោះអៀម ឈិន ។

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : រឿងនេះ គឺជាវិវាទប្តឹងលែងលះ និងបែងចែកទ្រព្យសម្បត្តិរួម សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ ។

-បានស្តាប់ចំលើយរបស់ឈ្មោះ តាំង ម៉ុន នៅពេលជំនុំជំរះថា : ប្តីខ្ញុំប្តឹងលែងលះខ្ញុំ និងចែកទ្រព្យសម្បត្តិ ខ្ញុំមិនយល់ព្រមទេ ព្រោះប្តីខ្ញុំឈ្មោះអៀម ឈិន គាត់បានចុះចោលខ្ញុំតាំងពីឆ្នាំ១៩៩៤ ។ ទ្រព្យសម្បត្តិរួមមានតែដីនៅពាធិចិនតុង ហើយមកចែកគ្នាស្មើ ខ្ញុំមិនព្រមទេ ។ ខ្ញុំចង់ជួបប្តីខ្ញុំដោយផ្ទាល់ ដើម្បីដោះស្រាយបញ្ហានេះ ។

-បានស្តាប់ចំលើយរបស់ឈ្មោះ លី សុវណ្ណ នៅពេលជំនុំជំរះថា : ចំពោះបញ្ហានេះ ដើមឡើយ ឪពុក និងម្តាយក្មេកខ្លួនបានមករស់នៅជាមួយក្រុមគ្រួសារលោកយាយតាំង ម៉ុន និងលោកតា អៀម ឈិន ហើយសព្វថ្ងៃនេះតា អៀម ឈិន បានមករស់នៅក្រុមគ្រួសាររបស់ខ្លួន ហើយលោកតា អៀម ឈិន បាន ផ្ទេរសិទ្ធិឱ្យខ្លួនដើម្បីដោះស្រាយបញ្ហានេះ ។ ខ្លួនសំណូមពរដល់ក្រុមប្រឹក្សាជំនុំជំរះតុលាការកំពូលមេត្តា តម្កល់សាលក្រមតុលាការក្រុងភ្នំពេញ និងសាលដីកាសាលាឧទ្ធរណ៍ទុកជាបានការទាំងមូល ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកស៊ឹម ស៊ីថាន មេធាវីការពារឱ្យចុងចម្លើយនៅពេលជំនុំជំរះ ថា : លោកតា អៀម ឈិន គាត់បានចុះចោលកូនក្តីខ្លួនតាំងពីឆ្នាំ១៩៨៤ មានបន្សល់ទុកដីមួយកន្លែង ហើយក្រោយមកទើបឈ្មោះអៀម ឈិន មកប្តឹងទាមទារ ។ ខ្លួនសូមជំទាស់សាលដីកាសាលាឧទ្ធរណ៍ លេខ១៤៨ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ទាំងមូល ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ចុងចម្លើយ ចម្លើយតំណាងដើមចោទ និងសេចក្តីសន្និដ្ឋានមេធាវីការពារចុងចម្លើយ .

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៣៦៣ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៥របស់អ្នកស្រីតាំង ម៉ុន ស្ថិតក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការ ចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា គូភាគីពិតជាប្តីប្រពន្ធមាននិតិសង្វាស់នឹងគ្នាប្រាកដមែន ប៉ុន្តែការរស់នៅមិនចុះ សម្រុងគ្នាឡើយ ហើយចុងចម្លើយក៏បានព្រមព្រៀងចំពោះការលែងលះនេះ កាលពីសវនាការនៅសាលា-ឧទ្ធរណ៍ដែរ ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ ក៏ដូចជាតុលាការក្រុងភ្នំពេញដែរ ដែលសម្រេចចែក ទ្រព្យរួមរបស់គូភាគីជា២ចំណែកស្មើគ្នានោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះថាតុលាការពុំទាន់បានពិចារណា ពីផលិតកម្មរបស់ចុងចម្លើយក្នុងអំឡុងពេលដែលដើមចោទបានចុះចោលលំនៅសង្វាស់តាំងតែពីឆ្នាំ១៩៨៤ ។

-យល់ឃើញថា ដើមចោទពុំបានចូលរួមនាសវនាការនេះទេ ប៉ុន្តែបានផ្ញើសារណាតបដាក់ជូនមក តុលាការកំពូលរួមហើយ ដូចនេះតុលាការកំពូលជំនុំជំរះកំបាំងមុខ ប៉ុន្តែចាត់ជាចំពោះមុខ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ១៤៨ "ឈ" ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៥ របស់ សាលាឧទ្ធរណ៍ដែលបានសំរេចមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់ រីឯគតិច្បាប់ខុសខ្លះត្រូវខ្លះ ។

## ហេតុដូច្នេះ

### *វិនិច្ឆ័យសេចក្តីចំពោះមុខចុងចម្លើយ កំបាំងមុខដើមចោទ*

### *ប៉ុន្តែចាត់ជាចំពោះមុខ :*

១-ទទួលបណ្តឹងសាទុក្ខលេខ៣៦៣ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៥ របស់អ្នកស្រី តាំង ម៉ុន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែគតិច្បាប់ខុសខ្លះត្រូវខ្លះ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ១៤៨"ឈ" ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ទុកជាបានការ លើកលែងតែចំណុចទី៤ នៃសាលក្រមរដ្ឋប្បវេណីលេខ២០៩"ង"ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៥ របស់តុលាការក្រុងភ្នំពេញ ត្រូវទុកជាមោឃៈ ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ៨៤៣ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០៥របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ លើចំណុចទី៤ នៃសាលក្រមរដ្ឋប្បវេណីលេខ២០៩"ង" ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៥ របស់តុលាការក្រុងភ្នំពេញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីដែលដើមចោទបានបង់នៅតុលាការកំពូលចំនួន១៩.០០០រៀលគឺ:

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ។

៥-សាលដីកានេះជំនុំជំរះ និងប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី២៤-១០-២០០៦ ។